១៣/០៣/៩៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

លេខ..217.......ប្រ.ក

# ប្រកាស

# ស្តីពី

# ការគ្រប់គ្រងពន្ធនាគារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

លេខ...217.....ប្រ.ក

# ប្រកាស

# ស្តីពី

# ការគ្រប់គ្រងពន្ធនាគារ

# រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីអំពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម. ០១៩៦.០៨ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ. ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃ ក្រសួងមហាផ្ទៃ
- បានឃើញការចាំបាច់របស់ក្រសួង

# សំរេច

## ប្រការ១: បទបញ្ញត្តិទូទៅ

### ១~ គោលបំណង

ក- ប្រកាសនេះ បង្កើតឡើង គឺក្នុងគោលបំណងដើម្បីផ្តល់សិទ្ធិអំណាចក្នុងការរៀបចំសន្តិសុខ របៀប រៀបរយក្នុងពន្ធនាគារ និងគ្រប់គ្រងអ្នកទោសឱ្យមានសណ្តាប់ធ្នាប់ និងសុវត្ថិភាពល្អក្នុងសង្គម ។

ខ- ប្រកាសនេះ ត្រូវអនុវត្តនៅគ្រប់ពន្ធនាគារទាំងអស់ ដែលស្ថិតនៅក្នុងឧបសម្ព័ន្ធ (ក) ។

គ- ប្រកាសនេះ ត្រូវអនុវត្តចំពោះអ្នកទោស មន្ត្រីនាយកដ្ឋានពន្ធនាគារ និងមន្ត្រីពន្ធនាគារគ្រប់រូប ដោយមិនប្រកាន់ពូជសាសន៍ ភេទ ពណ៌សម្បុរ ភាសា ទស្សនៈនយោបាយ សញ្ជាតិ សាសនា ស្ថានភាពសង្គម ភាពមានគតិ និងការអន់ថយផ្នែកកម្លាំងកាយ និងស្មារតី ។

### ២~ និយមន័យ

ក- ***ពន្ធនាគារ:*** គឺជាកន្លែងដែលបង្កើតឡើងស្របច្បាប់ សម្រាប់ឃុំអ្នកទោសតាមអំណាច នៃដីកា ឬការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់ពីតុលាការមានសមត្ថកិច្ច ។ ពន្ធនាគារមិនមែនជាកន្លែង សម្រាប់ស៊ើបអង្កេត ស្រាវជ្រាវ សួរចម្លើយ ឬធ្វើទារុណកម្ម និងមិនមែនជាកន្លែងប្រើប្រាស់សម្រាប់ ឃុំខ្លួនជនសង្ស័យរយៈពេល ៤៨ម៉ោង នោះដែរ ។

ខ- ***ពិរុទ្ធជន:*** គឺជាជនដែលតុលាការមិនទាន់កាត់ទោស ហើយត្រូវសន្មតថា ជាជនគ្មានកំហុស អាច ជាជនជាប់សង្ស័យ ឬជាជនជាប់ចោទ ក្នុងការប្រព្រឹត្តិបទល្មើសណាមួយ ហើយត្រូវបានឃុំខ្លួន ក្នុងមន្ទីរឃុំឃាំងស្របច្បាប់ តាមអំណាចដីកា រង់ចាំការសម្រេចបន្ថែមពីតុលាការ ។

គ- ***ទណ្ឌិត:*** គឺជាជនដែលតុលាការកាត់ទោសរួចហើយ ត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំងស្របច្បាប់ តាមអំណាចសាលក្រម និងការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់ពីតុលាការមានសមត្ថកិច្ច ។

ឃ- ***អ្នកទោស:*** គឺជាពិរុទ្ធជន ឬទណ្ឌិត ។

ង- ***មន្ត្រីពន្ធនាគារ:*** គឺអ្នកដែលបានបម្រើការងារក្នុងក្របខ័ណ្ឌនាយកដ្ឋានពន្ធនាគារកម្ពុជា ដើម្បី គ្រប់គ្រងអ្នកទោស ។

ច- *មន្ត្រីនាយកដ្ឋានពន្ធនាគារ:* គឺអ្នកដែលបម្រើការងារក្នុងក្របខ័ណ្ឌនាយកដ្ឋានពន្ធនាគារកម្ពុជា ដើម្បីជួយដល់ផ្នែករដ្ឋបាល និងកិច្ចប្រតិបត្តិការក្នុងពន្ធនាគារ ។

ឆ- *ប្រធានពន្ធនាគារ:* គឺអ្នកដែលទទួលបន្ទុកផ្នែករដ្ឋបាល និងកិច្ចប្រតិបត្តិការការងារប្រចាំថ្ងៃក្នុងពន្ធនាគារ ។

ជ- *ប្រធាននាយកដ្ឋានពន្ធនាគារ:* គឺអ្នកដែលទទួលខុសត្រូវរាល់សេចក្តីសម្រេចទាំងឡាយ ទាក់ទងនឹងផ្នែករដ្ឋបាល ភ័ស្តុភារ ការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ និងចាត់ចែងការងារទូទៅនៃពន្ធនាគារ ។

ឈ- *អ្នកផ្តល់ការថែទាំសុខភាព:* គឺជាមន្ត្រី ឬអង្គការណាមួយ ដែលបានអនុញ្ញាតយល់ព្រមពីប្រធាននាយកដ្ឋានពន្ធនាគារ ដើម្បីផ្តល់ការថែទាំសុខភាពអ្នកទោស ។

## ៣- អំណាច និង ការអនុវត្តន៍

ការអនុវត្តនីប្រកាសនេះ ត្រូវអនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា ដោយរួមទាំងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ ព្រមទាំងបទដ្ឋានអប្បបរមា សម្រាប់គ្រប់គ្រងអ្នកទោស ។

# ប្រការ ២: ការបង្កើតពន្ធនាគារ

១- ក្រសួងមហាផ្ទៃត្រូវទទួលខុសត្រូវរាល់ការបង្កើត ការគ្រប់គ្រង និងការផ្តល់ធនធានដល់ពន្ធនាគារទាំងអស់ឱ្យមានប្រសិទ្ធភាព ។

២- ឈ្មោះ និងទីកន្លែងនៃពន្ធនាគារនីមួយៗ ត្រូវចុះក្នុងបញ្ជីឧបសម្ព័ន្ធ (ក) នៃប្រកាសនេះ ។

៣- នាយកដ្ឋានពន្ធនាគារ មិនត្រូវប្រើប្រាស់ទីកន្លែងផ្សេងៗទៀតធ្វើជាពន្ធនាគារ ក្រៅពីពន្ធនាគារដែលមានចុះក្នុងឧបសម្ព័ន្ធ (ក) នៃប្រកាសនេះ ។

៤- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសុំការអនុញ្ញាតយល់ព្រមពីរាជរដ្ឋាភិបាល ដើម្បីបង្កើតពន្ធនាគារថ្មី បិទពន្ធនាគារដែលមានស្រាប់ ផ្លាស់ប្តូរឈ្មោះពន្ធនាគារ តាមសំណើពីប្រធាននាយកដ្ឋានពន្ធនាគារ ។

៥- ការបង្កើតពន្ធនាគារថ្មី បិទពន្ធនាគារដែលមានស្រាប់ ផ្លាស់ប្តូរឈ្មោះពន្ធនាគារនឹងចូលជាធរមាន ចាប់ពីថ្ងៃយល់ព្រមជាលាយលក្ខណ៍អក្សរ ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ប្រការ ៣: ការគ្រប់គ្រងពន្ធនាគារ

### ១- ភារកិច្ចចំបងៗ នៃ:

### ក- នាយកដ្ឋានពន្ធនាគារ

- គ្រប់គ្រងពន្ធនាគារនៅក្រសួង និងខេត្តក្រុងទាំងអស់ ឱ្យសមស្របតាមការកំណត់របស់ច្បាប់ និងសិទ្ធិមនុស្ស ។
- រៀបរៀងសេចក្តីព្រាង ប្រកាស នីតិវិធី បទបញ្ជា ស្តីពីការគ្រប់គ្រងពន្ធនាគារ គ្រប់គ្រងអ្នកទោសក្នុងទូទាំងប្រទេស ។
- កំណត់ចំនួនអ្នកទោស ដែលអាចទទួលយកបានក្នុងពន្ធនាគារនីមួយៗ ។
- ណែនាំ ដឹកនាំបញ្ជា ត្រួតពិនិត្យលើការងារ ការពារពន្ធនាគារ ការពារអ្នកទោស ។
- សហការជា មួយក្រសួងយុត្តិធម៌ សុខាភិបាល និងស្ថាប័នពាក់ព័ន្ធ ។
- ណែនាំ និងត្រួតពិនិត្យមើល តាមការកំណត់របស់រាជរដ្ឋាភិបាល និងក្រសួង ។
- ផ្គត់ផ្គង់របបហូបចុក សម្ភារៈប្រើប្រាស់ ការស្នាក់នៅ ការព្យាបាលសុខភាព ការរក្សាអនាម័យ និង គោលរបបឧបត្ថម្ភផ្សេងៗទៀតដល់អ្នកទោស ។
- ត្រួតពិនិត្យដឹកនាំ លើកសំណើ លើកគម្រោង លើការងារគ្រប់គ្រងឯកសារ ការងារបុគ្គលិក ការងារគណនេយ្យ ភ័ស្តុភារ ការងារសំណង់ស្ថាបនានៃកន្លែងធ្វើការរបស់មន្ត្រីទាំងអស់ កន្លែងឃុំឃាំងអ្នកទោសទូទៅ ទីតាំងនាយកដ្ឋានពន្ធនាគារ និងស្ថានភាពពន្ធនាគារ ។
- មន្ត្រីនាយកដ្ឋានពន្ធនាគារ និងមន្ត្រីពន្ធនាគារគ្រប់រូប ដែលបម្រើការងារក្នុងក្របខ័ណ្ឌនាយកដ្ឋានពន្ធនាគារ ត្រូវទទួលខុសត្រូវចំពោះមុខនាយកដ្ឋានពន្ធនាគារ ។
- ករណីចាំបាច់បន្ទាន់ នាយកដ្ឋានពន្ធនាគារ ឬប្រធានពន្ធនាគារអាចស្នើទៅអភិបាលខេត្ត-ក្រុង ស្នងការនគរបាលខេត្ត-ក្រុង ឬស្ថាប័នផ្សេងៗ ដើម្បីជួយពន្ធនាគារ ក្នុងការរក្សាសន្តិសុខ និងសុវត្ថិភាព ឬដើម្បីឱ្យមានការធានាជាលក្ខណៈមនុស្សធម៌ដល់អ្នកទោស និងមន្ត្រី ។

ខ- **ពន្ធនាគារ**

- ប្រធានពន្ធនាគារនីមួយៗ ត្រូវរៀបចំតាក់តែងបទបញ្ជាផ្ទៃក្នុងពន្ធនាគាររបស់ខ្លួន ហើយស្នើឡើងមកសុំការសម្រេចពីប្រធាននាយកដ្ឋានពន្ធនាគារ ។
- ប្រធានពន្ធនាគារ ត្រូវទទួលខុសត្រូវក្នុងការអនុវត្តន៍នីតិវិធី និងបទបញ្ជាផ្ទៃក្នុង ក្នុងពន្ធនាគាររបស់ខ្លួន ។
- ប្រធានពន្ធនាគារ ត្រូវចាត់វិធានការ ក្នុងការទទួលឃុំឃាំង និងដោះលែងអ្នកទោស ។
- បទបញ្ជាផ្ទៃក្នុងនោះ ត្រូវអនុលោមទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ ពាក់ព័ន្ធ ប្រកាស បទបញ្ជានានា គោលនយោបាយរបស់ក្រសួងមហាផ្ទៃ និងគោលនយោបាយ នីតិវិធីផ្សេងៗរបស់អគ្គនាយកដ្ឋានរដ្ឋបាល ។

## ២. មុខងារ និងការគាំទ្ររបស់មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារ

ក- ប្រធាននាយកដ្ឋានពន្ធនាគារ ត្រូវបានតែងតាំងដោយអនុក្រឹត្យ ។ អនុប្រធាននាយកដ្ឋានពន្ធនាគារ ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានពន្ធនាគារត្រូវបានតែងតាំងដោយ ប្រកាស ។

ខ- ពន្ធនាគារនីមួយៗ ត្រូវមានប្រធានពន្ធនាគារមួយរូប ហើយយ៉ាងហោចណាស់ត្រូវមានអនុប្រធាន ពន្ធនាគារមួយរូប អ្នកផ្តល់ការថែទាំសុខភាពមួយរូប និងមន្ត្រីពន្ធនាគារឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យ ការងារពន្ធនាគារដំណើរការមានប្រសិទ្ធភាពល្អ ។

គ- ការជ្រើសរើស ការបណ្តុះបណ្តាល ការតំលើងឋានៈ ការផ្ទេរពីកន្លែងមួយទៅកន្លែងមួយទៀត និងរាល់ការងាររដ្ឋបាលដទៃទៀត (រួមមានប្រាក់បៀវត្សរ៍ និងវិន័យ) ទាក់ទងទៅនឹងមុខងារ របស់មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារ ត្រូវអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន ដែលទាក់ទងដល់ការងារគ្រប់គ្រង បុគ្គលិករដ្ឋ ។ ការងាររបស់ស្ត្រី ត្រូវមានលក្ខខ័ណ្ឌដូចគ្នា នឹងបុរស ។

ឃ- នាយកដ្ឋានពន្ធនាគារ ត្រូវផ្តល់ការបណ្តុះបណ្តាលឱ្យបានសមស្របដល់មន្ត្រីនាយកដ្ឋាន និងមន្ត្រី ពន្ធនាគារទាំងអស់ នៅក្រោយពេលជ្រើសរើស ហើយត្រូវធានាឱ្យពួកគេមានជំនាញ និងចំណេះ

ដឹងចាំបាច់ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់នាយកដ្ឋាន ។ ជាពិសេសមន្ត្រីពន្ធនាគារ ដែលកំពុងធ្វើការ ក៏ត្រូវបានបណ្តុះបណ្តាលផងដែរ នូវចំណេះដឹងដូចខាងក្រោម :

- រចនាសម្ព័ន្ធ និងមុខងារនៃនាយកដ្ឋានពន្ធនាគារ ។
- ខ្លឹមសារនៃប្រកាស គោលនយោបាយ និងនីតិវិធីផ្សេងៗទៀត របស់នាយកដ្ឋាន ។
- ភារកិច្ច អំណាច និងការទទួលខុសត្រូវរបស់មន្ត្រីពន្ធនាគារ ។
- បទដ្ឋានស្តីពីសិទ្ធិមនុស្សអន្តរជាតិ ទាក់ទងទៅនឹងពន្ធនាគារ និងអ្នកទោស ។
- ពត៌មានពាក់ព័ន្ធផ្សេងៗ ស្តីពីពន្ធនាគារដែលពួកគេនឹងត្រូវទៅបម្រើការងារ ។

ង- មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារ ត្រូវបានគេផ្តល់នូវឱកាសក្នុងការថែរក្សា និងបង្កើនចំណេះដឹង និងសមត្ថភាពមុខជំនាញ ដោយចូលរួមក្នុងវគ្គសិក្សា ក្នុង និងក្រៅពន្ធនាគារ និងការបណ្តុះបណ្តាលក្នុង ពេលបម្រើការងារ ។

ច- មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារ (ប្តី-ប្រពន្ធ ឬកូនដែលនៅរស់) បើសិនជាមានការបាត់បង់សមត្ថភាពពលកម្ម ដោយផ្នែក ឬទាំងស្រុង ឬស្លាប់ដោយជម្ងឺ របួស គ្រោះថ្នាក់ ឬកើតឡើងដោយអំពើសងសឹក ត្រូវតែបានទទួលនូវការឧបត្ថម្ភ ។ ការជួយឧបត្ថម្ភនេះ នឹងត្រូវអនុលោមទៅតាមច្បាប់ និងគោលនយោបាយពាក់ព័ន្ធរបស់ក្រសួងមហាផ្ទៃ ។

ឆ- តម្រូវការដូចតទៅនេះ ត្រូវអនុវត្តលើពន្ធនាគារ ដែលឃុំឃាំងអ្នកទោសជាស្ត្រី :

- ពន្ធនាគារយ៉ាងហោចណាស់ត្រូវមានមន្ត្រីនាយកដ្ឋាន ឬមន្ត្រីពន្ធនាគារ ជាស្ត្រីភេទម្នាក់ ដែលបានទទួលការបណ្តុះបណ្តាល ដើម្បីផ្លាស់ប្តូរវេណត្រួតពិនិត្យពន្ធនាគារ ដែលដាក់អ្នកទោសស្ត្រីទាំងនោះ ។
- មន្ត្រីនាយកដ្ឋាន ឬមន្ត្រីពន្ធនាគារស្ត្រី ត្រូវអមដំណើរមន្ត្រីពន្ធនាគារជា បុរសពេលដែលពួកគេចូលអគារ បន្ទប់ឃុំឃាំងដាក់អ្នកទោសស្ត្រី ។
- ក្នុងស្ថានភាពសង្គ្រោះបន្ទាន់ អាយុជីវិត ឬសុខភាពអ្នកទោសស្ត្រី ដែលត្រូវគម្រាមកំហែងពេលអវត្តមានមន្ត្រីនាយកដ្ឋាន ឬមន្ត្រីពន្ធនាគារស្ត្រី មន្ត្រីនាយកដ្ឋាន ឬមន្ត្រីពន្ធនាគារបុរសដែលមានតួនាទីខ្ពស់ជាងគេ ហើយមានវត្តមាននៅទីនោះ ត្រូវចាត់វិធានការចាំបាច់ ដើម្បីជួយសង្គ្រោះអ្នកទោសស្ត្រីនោះសិន រួចទើបជូនដំណឹងដល់ប្រធានពន្ធនាគារ ។

## ៣- ភារកិច្ច និង ការទទួលខុសត្រូវរបស់មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារ

ក- ភារកិច្ច និងការទទួលខុសត្រូវផ្សេងៗរបស់ប្រធាននាយកដ្ឋានពន្ធនាគារ និងមន្ត្រីទទួលខុសត្រូវសំខាន់ៗក្នុងនាយកដ្ឋានពន្ធនាគារ នឹងត្រូវបានចែងនៅក្នុងសេចក្តីកំណត់ស្តីពីការបែងចែកតួនាទីភារកិច្ចក្នុងនាយកដ្ឋានពន្ធនាគារ ដែលចេញដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ខ- ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារដទៃទៀត នឹងត្រូវបានចែងក្នុងសេចក្តីកំណត់ស្តីពីការបែងចែកតួនាទី ភារកិច្ច ដែលចេញដោយនាយកដ្ឋានពន្ធនាគារ ។

គ- ប្រធាននាយកដ្ឋានពន្ធនាគារត្រូវណែនាំដល់មន្ត្រីនាយកដ្ឋានពន្ធនាគារ ឱ្យពិនិត្យសើរើយ៉ាងទៀងទាត់លើសេចក្តីកំណត់ស្តីពីការបែងចែកតួនាទី ភារកិច្ច ដែលចេញឱ្យមន្ត្រី នាយកដ្ឋាន និងមន្ត្រីពន្ធនាគារសម្រាប់អនុវត្ត ។

ឃ- មន្ត្រីនាយកដ្ឋានពន្ធនាគារ និងមន្ត្រីពន្ធនាគារដែលមានបេសកកម្មដឹកនាំបញ្ជូន ការពារអ្នកទោសដេកពេទ្យ ធ្វើដំណើរឡើងចុះ ប្រជុំរៀនសូត្រ បើករបបសម្ភារៈ ។ល។ ត្រូវបានផ្តល់ប្រាក់បំណាច់បេសកកម្មក្នុងប្រទេស ដូចមានចែងនៅក្នុងអនុក្រឹត្យ ។

## ៤- វិន័យរបស់មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារ

មន្ត្រីនាយកដ្ឋាន ឬមន្ត្រីពន្ធនាគារណាម្នាក់ ដែលធ្វេសប្រហែស ពុករលួយ មិនគោរពភារកិច្ចរបស់ខ្លួនដោយចេតនា បណ្តាលឱ្យអ្នកទោសរត់គេចពីពន្ធនាគារ ឬកន្លែងឃុំឃាំងស្របច្បាប់ ឬបានរំលោភបំពានទៅលើប្រកាសនេះ នីតិវិធីផ្សេងៗរបស់ពន្ធនាគារ ឬបទបញ្ជាផ្ទៃក្នុងពន្ធនាគា ត្រូវទទួលវិន័យ ស្របទៅនឹងគោលនយោបាយរបស់ក្រសួង និងត្រូវទទួលទណ្ឌកម្មទៅតាមច្បាប់ព្រមទាំងលិខិតបទដ្ឋាននានាជាធរមាន ។

# ប្រការ ៤: ចំណាត់ការអ្នកទោស

## ១- ការទទួលយកចូល

ក- ពន្ធនាគារនីមួយៗ ត្រូវទទួលយកតែអ្នកទោសណា ដែលបញ្ជូនមក ដោយមានដីកាឃុំខ្លួន ឬសាលក្រម ឬការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់ពីតុលាការមានសមត្ថកិច្ច ។

ខ- ពន្ធនាគារនីមួយៗ ត្រូវរក្សាបញ្ជីឈ្មោះអ្នកទោស ។ បញ្ជីនោះត្រូវមានលេខរៀងបន្តបន្ទាប់លើទំព័រនីមួយៗ ហើយត្រូវមានពត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់អ្នកទោសម្នាក់ៗ មូលហេតុនៃការឃុំខ្លួន សេចក្ដីលំអិតស្ដីពីការកាត់ទោស និងការដោះលែង ព្រមទាំងពត៌មានផ្សេងៗទៀតដែលតម្រូវដោយនាយកដ្ឋានពន្ធនាគារ ។

គ- អ្នកផ្ដល់ការថែទាំសុខភាព ត្រូវពិនិត្យឡើងវិញនូវលក្ខណៈសុខភាពរបស់អ្នកទោសទាំងអស់ ឱ្យបានឆាប់បំផុត បន្ទាប់ពីការទទួលយកអ្នកទោសចូលក្នុងពន្ធនាគារ ។ បើសិនជាអ្នកទោសណាម្នាក់មានជម្ងឺ ឬមានរបួស នៅពេលទទួលយកចូលក្នុងពន្ធនាគារ ប្រធានពន្ធនាគារត្រូវរៀបចំព្យាបាលសុខភាពឱ្យបានឆាប់បំផុត បើអាចធ្វើទៅបាន ហើយត្រូវសរសេរលំអិតពីរបួស ឬជម្ងឺនីមួយៗ នៅក្នុងឯកសារផ្ទាល់ខ្លួនរបស់អ្នកទោស ។

ឃ- បន្ទាប់ពីទទួលយកចូលក្នុងពន្ធនាគារ អ្នកទោសគ្រប់រូប ត្រូវបានអនុញ្ញាតឱ្យរកមេធាវី ក្នុងគោលបំណងប្ដឹងឧទ្ធរណ៍ ឬដោះស្រាយបញ្ហាពាក់ព័ន្ធរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ដែលមិនទាន់ដោះស្រាយរួចនៅឡើយ ។

ង- ត្រូវថតរូបអ្នកទោសជាបន្ទាន់ បន្ទាប់ពីការយកចូលក្នុងពន្ធនាគាររួចមក ហើយត្រូវថតរូបអ្នកទោសនោះ ជាបន្តបន្ទាប់ទៀត បើសិនជារូបរាងកាយរបស់គេ មានការផ្លាស់ប្ដូរគួរឱ្យកត់សំគាល់ ។

ច- អ្នកទោសទាំងអស់ ត្រូវបានអនុញ្ញាតឱ្យផ្ដល់ពត៌មានទៅគ្រួសារ ឬសាច់ញាតិរបស់ខ្លួន អំពីការជាប់ពន្ធនាគារ បន្ទាប់ពីទទួលយកចូលក្នុងពន្ធនាគារ ។

ឆ- នៅពេលទទួលយកចូល អ្នកទោសជាជនបរទេស ត្រូវបានគេផ្ដល់ពត៌មានជាភាសាណាមួយដែលគេអាចយល់បានអំពីសិទ្ធិជូន ដំណឹងទៅស្ថានទូត ស្ថានកុងស៊ុល ឬអង្គការពាក់ព័ន្ធដទៃទៀតរបស់ខ្លួន អំពីការជាប់ពន្ធនាគារ និងត្រូវបានផ្ដល់ឱកាសដ៏សមហេតុផល ដើម្បីធ្វើការងារនេះបន្ទាប់ពីទទួលយកចូលក្នុងពន្ធនាគារ ។ បើសិនជាអ្នកទោសជាជនបរទេស មិនអាចផ្ដល់ពត៌មានជូនស្ថានទូត ស្ថានកុងស៊ុល ឬអង្គការពាក់ព័ន្ធរបស់ខ្លួនបានទេនោះ ប្រធានពន្ធនាគារ ត្រូវបំពេញការងារនេះជាបន្ទាន់ ជំនួសអ្នកទោស ដោយអនុលោមតាមនីតិវិធីពន្ធនាគារ ។

ជ- នៅពេលទទួលយកចូលក្នុងពន្ធនាគារ អ្នកទោសគ្រប់រូប ត្រូវបានគេណែនាំពីសិទ្ធិរបស់ខ្លួន និងត្រូវរៀនសូត្រពីបទបញ្ជាផ្ទៃក្នុងពន្ធនាគារ និងនីតិវិធីផ្សេងៗ ដែលបានអនុញ្ញាត ដើម្បីស្វែងរក

ពតិមាន ឬធ្វើការប្តឹងតវ៉ាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ប៉ុន្តែត្រូវស្ថិតក្នុងទម្រង់ និងភាសាណាមួយ ដែលអ្នកទោសអាចយល់បាន ។

## ២_ ចំណាត់ថ្នាក់

ក- ចំណាត់ថ្នាក់សន្តិសុខផ្សេងៗ ត្រូវបានកំណត់ស្របតាមនីតិវិធីពន្ធនាគារ ។

ខ- ប្រធានពន្ធនាគារ ត្រូវទទួលខុសត្រូវចំពោះការកំណត់ និងការពិនិត្យឡើងវិញ ចំណាត់ថ្នាក់សន្តិសុខរបស់អ្នកទោស ទាំងអស់នៅក្នុងពន្ធនាគារ ។

## ៣_ ការបំបែក

ក- អ្នកទោសស្ត្រី និងអ្នកទោសបុរស ត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា ។

ខ- អ្នកទោសដូចខាងក្រោមនេះ ត្រូវដាក់ឱ្យនៅដោយឡែកពីគ្នា បើសិនអគារពន្ធនាគារអាចធានាដាក់បាន :

- ត្រូវដាក់អ្នកទោសដែលមានអាយុក្រោម១៨ឆ្នាំ ឱ្យនៅដោយឡែកពីអ្នកទោស ដែលមានវ័យចាស់ ។
- ត្រូវដាក់ពិរុទ្ធជន ឱ្យនៅដោយឡែកពីទណ្ឌិត ។
- អ្នកទោសដែលរត់គេចខ្លួនពីពន្ធនាគារ ឬបានប្រព្រឹត្តផ្ទុយនឹងសន្តិសុខសណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារ ។
- អ្នកទោសកម្រិតធ្ងន់ ឱ្យនៅដោយឡែកពីអ្នកទោសកម្រិតស្រាល ។
- អ្នកទោសដែលមានជម្ងឺផ្លូវកាយ ផ្លូវចិត្តឬរបួស ដែលប៉ះពាល់ដល់សុខភាព និងសុខុមាលភាពរបស់ខ្លួន ឬអ្នកទោសដទៃទៀត ។

## ៤_ ការដោះលែង

ក- អ្នកទោសត្រូវបានដោះលែងជាបន្ទាន់ ក្នុងកាលៈទេសៈដូចតទៅនេះ :

- នៅពេលផុតកំណត់ទោស
- នៅពេលអនុញ្ញាតឱ្យដាក់ប្រាក់ធានាឱ្យនៅក្រៅឃុំ ដោះលែងដោយមានលក្ខខ័ណ្ឌ ដោះលែងបណ្តោះអាសន្ន ។
- នៅពេលលើកលែងការចោទប្រកាន់ ។
- នៅពេលនិរទេសខ្លួនទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច ដោយមានការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់ពីតុលាការមានសមត្ថកិច្ច ។
- នៅពេលលើកលែងទោសដោយព្រះមហាក្សត្រចំពោះទោសដែលនៅសេសសល់ ។

ខ- ប្រធាននាយកដ្ឋាន ត្រូវធានាថា រាល់សំណុំឯកសារទាក់ទងការដោះលែងអ្នកទោស ត្រូវបានចុះហត្ថលេខានៅថ្ងៃដោះលែងនោះ ឬប្រធាននាយកដ្ឋានអាចអនុញ្ញាតជាលាយលក្ខណ៍អក្សរឱ្យមន្ត្រីនាយកដ្ឋាន ឬប្រធានពន្ធនាគារ ចុះហត្ថលេខាជំនួស ។

គ- នៅពេលដែលអ្នកទោសណាម្នាក់ត្រូវបានដោះលែង ប្រធានពន្ធនាគារត្រូវផ្តល់ឱ្យអ្នកទោសនោះនូវច្បាប់ចម្លង សំណុំឯកសារដោះលែងចំនួនមួយច្បាប់ ហើយត្រូវរក្សាទុកនូវច្បាប់ដើម ។

ឃ- ប្រធានពន្ធនាគារ ចាំបាច់ត្រូវផ្តល់ពត៌មានទៅអាជ្ញាធរមូលដ្ឋាន អំពីការដោះលែងអ្នកទោសតាមនីតិវិធីពន្ធនាគារ ។

ង- អ្នកទោសគ្រប់រូប ដែលជាប់ឃុំរយៈពេលមួយឆ្នាំឡើងទៅ នៅពេលត្រូវដោះលែង ត្រូវបានទទួលការឧបត្ថម្ភតាមរបបគោលនយោបាយដោះលែង ។

## ៥~ ការផ្ទេរ ឬការយកចេញ

ក- ការផ្ទេរអ្នកទោសណាម្នាក់ ជាលក្ខណៈរដ្ឋបាល អាចធ្វើទៅបាន នៅពេលដែលមានសំណើសុំជាលាយលក្ខណ៍អក្សរតាមរយៈប្រធាននាយកដ្ឋានពន្ធនាគារ ។

ខ- នៅពេលផ្ទេរអ្នកទោសទៅកាន់ពន្ធនាគារណាមួយ ប្រធានពន្ធនាគារត្រូវរៀបចំបញ្ជូនសំណុំឯកសារទាំងអស់របស់អ្នកទោស របាយការណ៍ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកគេទៅឱ្យប្រធានពន្ធនាគារដែលត្រូវផ្ទេរទៅ ។ បញ្ជីផ្ទេរអ្នកទោស ត្រូវចុះហត្ថលេខាទទួលដោយប្រធានពន្ធនាគារ ហើយត្រូវប្រគល់អត្ថបទចម្លងមួយច្បាប់ទៅមន្ត្រីទទួលបន្ទុកការផ្ទេរនោះវិញ ។ អ្នកទោសទាំងឡាយ

ដែលបានផ្ទេរទៅកាន់ពន្ធនាគារមួយទៀត ត្រូវបានគេផ្តល់ឱកាស ដើម្បីជូនដំណឹងទៅ ក្រុមគ្រួសារ ឬសាច់ញាតិភ្លាមៗបន្ទាប់ពីការផ្ទេរនោះ ។

គ- ក្នុងការយកអ្នកទោសចេញ ប្រធានពន្ធនាគារត្រូវមានលិខិតជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីមូលហេតុដូចខាងក្រោម :

- បន្ទាប់ពីអ្នកថែទាំសុខភាព ពិនិត្យឃើញថា អ្នកទោសណាម្នាក់មានជម្ងឺ មានរបួស ដែលតម្រូវឱ្យពិនិត្យព្យាបាលនៅមណ្ឌលសុខភាពខាងក្រៅ ដូចជាមន្ទីរពេទ្យជាដើម ។
- នៅពេលដែលអ្នកទោសណាម្នាក់ ត្រូវបានអនុញ្ញាតឱ្យធ្វើការនៅក្រៅពន្ធនាគារ ។

ឃ- ការយកអ្នកទោសចេញទៅបង្ហាញខ្លួន ដូចខាងក្រោមត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីតុលាការ :

- ពេលឡើងសវនាការ
- ពេលឡើងឧទ្ធរណ៍
- ពេលស៊ើបសួរពតិមាន ឬការស៊ើបអង្កេត
- ពេលផ្តល់វត្ថុតាង

ង- នៅពេលអ្នកទោសត្រូវបានផ្លាស់ប្តូរទៅពន្ធនាគារ ឬមកពីពន្ធនាគារមួយផ្សេងទៀត ការផ្លាស់ប្តូរនោះត្រូវធ្វើឡើងដោយសេចក្តីថ្លៃថ្នូរ និងការពារសុវត្ថិភាពឱ្យបានត្រឹមត្រូវ ។

ច- អ្នកទោសដែលតម្រូវឱ្យបង្ហាញខ្លួនចំពោះមុខតុលាការ ត្រូវអនុញ្ញាតឱ្យស្លៀកពាក់សម្លៀកបំពាក់ស្អាតបាត និង សមរម្យ ផ្ទាល់ខ្លួនរបស់គេ ។

ឆ- គ្មានអ្នកទោសណាម្នាក់ ត្រូវបានគេអនុញ្ញាតឱ្យស្នាក់នៅខាងក្រៅពន្ធនាគារ ឬត្រូវបានគេអនុញ្ញាតឱ្យចេញក្រៅពន្ធនាគារនៅពេលយប់បានឡើយ លើកលែងតែមានករណីសង្គ្រោះបន្ទាន់ណាមួយតែប៉ុណ្ណោះ ។

ជ- គ្មានអ្នកទោសណាម្នាក់ អាចត្រូវបានគេផ្លាស់ប្តូរ ឬផ្ទេរពីពន្ធនាគារ ក្នុងករណីបន្ទាន់ណាមួយឡើយ លើកលែងតែមានហេតុផលមួយចំនួនដូចខាងក្រោម :

- ពន្ធនាគារមានអ្នកទោសច្រើនលើសលប់
- សន្តិសុខពន្ធនាគារមិនអាចធានាបាន
- គ្រោះមហន្តរាយ (រួមមានគ្រោះធម្មជាតិ ដែលបានកើតឡើងក្នុងពន្ធនាគារ) ។

ឈ- បើសិនជាគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុន ពីនាយកដ្ឋានពន្ធនាគារ ។ ក្នុងការយកចេញ ឬផ្ទេរអ្នកទោសណាម្នាក់ ក្នុងករណីសង្គ្រោះបន្ទាន់ ប្រធានពន្ធនាគារមានសិទ្ធិសម្រេចបាន ប៉ុន្តែត្រូវរាយការណ៍ជាបន្ទាន់ នូវមូលហេតុនោះជូនប្រធាននាយកដ្ឋានពន្ធនាគារ ។

## ៦. ពត៌មានពាក់ព័ន្ធនឹងពន្ធនាគារ

ក- បុគ្គល ឬអង្គការក្រៅរដ្ឋាភិបាល ដែលមានគោលបំណងស្នើសុំពត៌មានផ្សេងៗ ទាក់ទងនឹងពន្ធនាគារ ត្រូវមានការស្នើសុំមកប្រធាននាយកដ្ឋានពន្ធនាគារ ។

ខ- មន្ត្រីនាយកដ្ឋាន ឬមន្ត្រីពន្ធនាគារណាម្នាក់ ដែលបានទទួល និងប្រើប្រាស់ពត៌មាន សម្រាប់ប្រយោជន៍ផ្ទាល់ខ្លួន ឬផ្តល់ពត៌មានទៅបុគ្គល ឬអង្គការក្រៅរដ្ឋាភិបាលណាមួយ ដែលគ្មានការអនុញ្ញាត ត្រូវទទួលវិន័យតាមប្រកាសនេះ ។

## ៧. សិទ្ធិរបស់អ្នកទោស

ក: សិទ្ធិរបស់អ្នកទោសដែលបានចែងក្នុងប្រការនេះ ហើយបន្ថែមនឹងសិទ្ធិដទៃទៀត ដែលបានចែងក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា (រួមមានគោលការណ៍សន្ធិសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិនយោបាយ សិទ្ធិពលរដ្ឋ និងវិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ ស្តីពីការគ្រប់គ្រងអ្នកទោស) ត្រូវបានគេធានា ។

ខ- អ្នកទោសគ្រប់រូប ត្រូវមានសិទ្ធិដូចខាងក្រោមនេះ :

- សិទ្ធិត្រូវបានគេថែទាំ ក្នុងសភាពថ្លៃថ្នូរ និងមានតម្លៃជាមនុស្ស ។
- សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម អំពើព្រៃផ្សៃ អមនុស្សធម៌ ឬបន្ទាបបន្ថោក និងដាក់ ទណ្ឌកម្ម
- សិទ្ធិលំហែកាយ យ៉ាងហោចណាស់ឱ្យបានមួយម៉ោងក្នុងមួយថ្ងៃ តាមអាកាសធាតុផ្តល់ឱ្យ ក្នុងករណីគ្មានការអនុញ្ញាតឱ្យចេញទៅធ្វើការនៅខាងក្រៅ ក្នុងរយៈពេលដូចគ្នា ។
- មានសិទ្ធិទទួលដឹងឮពីកំហុសរបស់ខ្លួន មុនពេលទទួលវិន័យ ។

- សិទ្ធិទទួលម្ហូបអាហារ និងទឹកស្អាតគ្រប់គ្រាន់ ដើម្បីថែរក្សាសុខភាព សិទ្ធិទទួលនូវអាហារពិសេសប្រចាំថ្ងៃ នៅពេលណាប្រធានពន្ធនាគារយល់ឃើញថា ចំណីអាហារនេះត្រូវការចាំបាច់តាមវេជ្ជបញ្ជា ឬតាមជំនឿសាសនារបស់ពួកគេ ។
- សិទ្ធិទទួលសម្លៀកបំពាក់ស្អាត ស្របតាមអាកាសធាតុ និងការងារឱ្យបានគ្រប់គ្រាន់ ដើម្បីរក្សាសុខភាពពួកគេ ។
- សិទ្ធិទទួលការថែទាំ និងព្យាបាលចាំបាច់ផ្សេងទៀត ផ្នែកសុខភាព និងធ្មេញ ។
- សិទ្ធិទទួលការថែទាំ និងព្យាបាលពិសេស បើមានជម្ងឺផ្នែកស្មារតី និងផ្លូវចិត្ត ។
- សិទ្ធិជ្រើសរើសជំនឿសាសនា សមស្របនឹងសន្តិសុខ សណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារ ។ សិទ្ធិចូលរួមជំនឿសាសនាជាមួយអ្នកទោសផ្សេងទៀត ។
- សិទ្ធិស្នើសុំ ឬប្តឹងតវ៉ា ក្នុងការថែទាំរូបរាងកាយតាមលក្ខណៈធម្មជាតិ ។
- សិទ្ធិក្នុងការជូនដំណឹងនានា ទៅកាន់ក្រុមគ្រួសាររបស់គេភ្លាម បន្ទាប់ពីជាប់ពន្ធនាគារ ឬផ្លាស់ប្តូរទៅកាន់ពន្ធនាគារផ្សេងទៀត ក្នុងករណីអ្នកទោសជាជនបរទេស គឺមានសិទ្ធិជូនដំណឹងទៅកាន់ស្ថានទូតស្ថានកុងស៊ុល និងអង្គការពាក់ព័ន្ធ ។
- សិទ្ធិទទួលជួបសួរសុខទុក្ខ ពីគ្រួសារ និងមិត្តភ័ក្តិ យ៉ាងហោចណាស់មួយម៉ោងក្នុងមួយសប្តាហ៍ ។
- សិទ្ធិទទួលការបែងចែកចំណាត់ថ្នាក់ជាបន្ទាន់ បន្ទាប់ពីមានការកាត់ទោស ហើយត្រូវពិនិត្យសើរើឡើងវិញជាប្រចាំ ។
- ការទាក់ទងតាមសំបុត្រស្នាម និងការពិគ្រោះយោបល់ជាមួយមេធាវី ត្រូវធ្វើឡើងដោយគ្មានការផ្លាស់ប្តូរខ្លឹមសារ ពន្យារពេល និងរក្សាការសម្ងាត់ ។ ការទាក់ទង ពិគ្រោះយោបល់នេះ ត្រូវស្ថិតក្នុងលក្ខខ័ណ្ឌសមហេតុផល ដើម្បីធានាសន្តិសុខ និងសណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារ ។
- សិទ្ធិផ្ញើ និងទទួលលិខិតពីក្រុមគ្រួសារ និងមិត្តភ័ក្តិ ។
- សិទ្ធិចូលរួមក្នុងកម្មវិធីវប្បធម៌ អប់រំ រៀនសូត្រ កំសាន្ត និងវិជ្ជាជីវៈក្នុងពន្ធនាគារ ហើយមានសិទ្ធិប្រើប្រាស់សម្ភារៈគ្រប់គ្រាន់ និងសមរម្យ ដើម្បីអនុវត្តកម្មវិធីសិក្សាឱ្យមានប្រសិទ្ធភាព ។

## ៨- ការបែងចែកសម្លៀកបំពាក់ និងសម្ភារៈបរិក្ខារ

ក- អ្នកទោសម្នាក់ៗ ត្រូវបានគេផ្តល់ឱ្យនូវសម្លៀកបំពាក់ ស្របទៅតាមភេទ និងអាកាសធាតុ ដោយរាប់បញ្ចូលទាំងសម្លៀកបំពាក់ប្រើប្រាស់ជាទូទៅ សម្រាប់ធ្វើការ និងសម្រាប់លំហែកាយ ព្រមទាំងសម្ភារៈបរិក្ខារផ្ទាល់ខ្លួន ដោយរួមទាំងសម្ភារៈអនាម័យផង ។

ខ- នាយកដ្ឋានពន្ធនាគារ ត្រូវកំណត់ និងផ្តល់គំរូ ចំនួន និងពណ៌សម្លៀកបំពាក់របស់អ្នកទោស ។

គ- អ្នកទោសត្រូវថែរក្សាអនាម័យ សម្លៀកបំពាក់ និងសម្ភារៈបរិក្ខារ ផ្ទាល់ខ្លួនឱ្យបានស្អាតល្អ លើកលែងតែអ្នកទោសនោះបាត់បង់សមត្ថភាពពលកម្ម ។

ឃ- សម្លៀកបំពាក់ និងសម្ភារៈដែលបើកឱ្យអ្នកទោស ត្រូវប្តូរនៅពេលរហែក បាត់បង់ ឬមិនអាចជួសជុលបាន ។

ង- ប្រធានពន្ធនាគារ អាចអនុញ្ញាតឱ្យអ្នកទោសប្រើប្រាស់សម្លៀកបំពាក់ផ្ទាល់ខ្លួនបាន បើសិនជាសម្លៀកបំពាក់ទាំងនោះ ស្អាត និងសមរម្យ មិនប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងសន្តិសុខល្អក្នុងពន្ធនាគារ ជាពិសេសពេលឡើងសវនាការ ។

## ៩- ការផ្តល់ម្ហូបអាហារ

ក- អ្នកទោសគ្រប់រូប ត្រូវបានគេផ្តល់ម្ហូបអាហារ ដែលមានជីវជាតិគ្រប់គ្រាន់ជារៀងរាល់ថ្ងៃ តាមរបបប្រចាំថ្ងៃ ដែលរដ្ឋបានកំណត់ ដើម្បីទ្រទ្រង់សុខភាព និងសុខុមាលភាពរបស់ពួកគេ ។

ខ- អ្នកទោសអាចទទួល ឬទិញម្ហូបអាហារបន្ថែមពីខាងក្រៅពន្ធនាគារបាន ដោយមានការអនុញ្ញាតពីប្រធានពន្ធនាគារ ។ ម្ហូបអាហារទាំងនោះ ត្រូវត្រួតពិនិត្យពីមន្ត្រីពន្ធនាគារ មុននឹងផ្តល់ឱ្យ ។

គ- អ្នកទោសត្រូវបានគេផ្តល់អាហារប្រចាំថ្ងៃ តាមពេលកំណត់ដោយប្រធានពន្ធនាគារ ។ ប៉ុន្តែជាទូទៅ ត្រូវផ្តល់អាហារពេលព្រឹក ម៉ោង១០:៣០នាទី និងពេលល្ងាចម៉ោង ៤:៣០នាទី ។

ឃ- អ្នកទោសត្រូវបានទទួលទឹកស្អាតគ្រប់គ្រាន់ សម្រាប់បរិភោគគ្រប់ពេលវេលា ។

## ១០- អ្នកសួរសុខទុក្ខ

ក- ពេលម៉ោងសម្រាប់សួរសុខទុក្ខត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ។

ខ- ក្នុងអំឡុងពេលម៉ោង ដែលអនុញ្ញាតឱ្យសួរសុខទុក្ខ អ្នកទោសអាចជួបជាមួយ :

- ក្រុមគ្រួសារ មិត្តភ័ក្តិ រយៈពេលមួយម៉ោងជាអប្បបរមា ក្នុងមួយសប្តាហ៍ ។ អ្នកដែលមានអាយុក្រោម១៨ឆ្នាំ មិនត្រូវអនុញ្ញាតឱ្យសួរសុខទុក្ខអ្នកទោសបានឡើយ លុះណាតែមានមនុស្សចាស់មកជាមួយ ឬមានការអនុញ្ញាតយល់ព្រមពីប្រធានពន្ធនាគារ ។
- មេធាវីរបស់ពួកគេ ។
- ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាល ក្នុងបំណងធ្វើសម្ភាសន៍ ។ ការសម្ភាសន៍ត្រូវធ្វើឡើងនៅ ចំពោះមុខមេធាវីរបស់អ្នកទោស ។ ក្នុងពេលអវត្តមានមេធាវី ការសម្ភាសន៍ត្រូវធ្វើឡើង ដោយមានវត្តមានរបស់មន្ត្រីនាយកដ្ឋាន ឬមន្ត្រីពន្ធនាគារ ។
- អ្នកតំណាងស្ថានទូត ស្ថានកុងស៊ុលរបស់ពួកគេ ដោយជូនដំណឹងជាមុនទៅកាន់ប្រធាននាយកដ្ឋានពន្ធនាគារ ។

គ- អ្នកមកសួរសុខទុក្ខមិនត្រូវយកមកជាមួយនូវវត្ថុ ឬសម្ភារៈហាមឃាត់ តាមការជូនដំណឹងរបស់ប្រធានពន្ធនាគារ ។

ឃ- ហាមថតរូប ថតសម្លេង ថតវីដេអូ ទាំងអ្នកទោស ទាំងបរិវេណ ស្ថានភាពពន្ធនាគារ លើកលែងតែមានការអនុញ្ញាតពីប្រធាននាយកដ្ឋានពន្ធនាគារ និងពីអ្នកទោស ។

## ១១- ការជូនដំណឹងពីជម្ងឺ ឬមរណភាពរបស់សមាជិកគ្រួសារ

បើអាចធ្វើទៅបាន អ្នកទោសត្រូវបានគេជូនដំណឹងជាបន្ទាន់ នៅពេលដែលបានទទួលដំណឹងថា ឪពុកម្តាយ សមាជិកគ្រួសារជិតដិត មានគ្រោះថ្នាក់ ជម្ងឺធ្ងន់ ឬទទួលមរណភាព ។

## ១២- ទំនាក់ទំនងតាមលិខិតស្នាម

លិខិតឆ្លើយឆ្លង ដែលអ្នកទោសបានទទួល ឬបានផ្ញើ ត្រូវឆែកឆេររកវត្ថុហាមឃាត់ ដោយប្រធានពន្ធនាគារ ចំពោះមុខអ្នកទោសលើកលែងតែមានលិខិតពីមេធាវី ។

## ១៣- ទំនាក់ទំនងអ្នកទោសជាមួយមជ្ឈដ្ឋានខាងក្រៅ

អ្នកទោសអាចទទួលពត៌មាន ដែលមិនប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់ល្អពន្ធនាគារ តាមរយៈការប្រើប្រាស់វិទ្យុ សារពត៌មាន និងទូរទស្សន៍ ។ អ្នកទោសអាចទិញវិទ្យុ សារពត៌មាន និងទូរទស្សន៍មកប្រើប្រាស់ ដោយចំណាយថវិកាផ្ទាល់ខ្លួន ឬទទួលពីមជ្ឈដ្ឋានខាងក្រៅ ។

## ១៤~ ទ្រព្យសម្បត្តិ

ក- ទ្រព្យសម្បត្តិរបស់អ្នកទោស ដូចជាលុយកាក់ គ្រឿងអលង្ការ វត្ថុមានតម្លៃ និងសម្ភារៈផ្សេងៗទៀត ដែលប្រធានពន្ធនាគារហាមឃាត់ មិនត្រូវរក្សាទុកនៅជាប់ខ្លួនអ្នកទោសឡើយ ។ វត្ថុទាំងអស់ ដែលដកហូត ត្រូវកត់ចូលក្នុងបញ្ជី ។ ពន្ធនាគារត្រូវរក្សាទ្រព្យសម្បត្តិដែលបានដកហូតពីអ្នកទោស ឱ្យគង់វង្សល្អ ហើយត្រូវប្រគល់ឱ្យអ្នកទោសវិញ នៅថ្ងៃដោះលែង ។

ខ- អ្នកទោសទាំងអស់ អាចស្នើសុំដកយកលុយ ឬទ្រព្យសម្បត្តិរបស់ខ្លួនពីប្រធានពន្ធនាគារ ដែលបានតម្កល់ទុកក្នុងបញ្ជីទ្រព្យសម្បត្តិរបស់ពួកគេ ដោយអនុលោមតាមនីតិវិធីពន្ធនាគារ ។ ចំនួនលុយ ឬទ្រព្យសម្បត្តិ ដែលបានដកឱ្យអ្នកទោសត្រូវសរសេរជាលាយលក្ខណ៍អក្សរ ក្នុងបញ្ជីទ្រព្យសម្បត្តិ ដោយមានបង្កាន់ដៃចុះហត្ថលេខា ឬផ្តិតមេដៃដោយអ្នកទោស ជាសំអាង ។

គ- ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នកទោស អាចផ្តល់ទៅឱ្យអ្នកដែលនៅខាងក្រៅពន្ធនាគារបាន ។ ទ្រព្យសម្បត្តិទាំងនោះ ត្រូវចុះនៅក្នុងសៀវភៅកំណត់ហេតុទ្រព្យសម្បត្តិរបស់អ្នកទោស ហើយត្រូវចុះហត្ថលេខា និងផ្តិតមេដៃដោយអ្នកទោស និងអ្នកដែលបានទទួលទ្រព្យសម្បត្តិនោះផង ។

ឃ- អ្នកទោសអាចទទួលទ្រព្យសម្បត្តិផ្ទាល់ខ្លួនពីជនណាម្នាក់ ដែលនៅក្រៅពន្ធនាគារ ។ សម្ភារៈទាំងនេះ ត្រូវចុះក្នុងបញ្ជីទ្រព្យសម្បត្តិអ្នកទោស ហើយត្រូវចុះហត្ថលេខា ឬផ្តិតមេដៃដោយអ្នកទោស និងអ្នកប្រគល់ទ្រព្យសម្បត្តិនោះ ។

ង- អ្នកទោសដែលមានថ្នាំសង្កូវជាប់នឹងខ្លួន ត្រូវមានការអនុញ្ញាតយល់ព្រមពីអ្នកថែទាំសុខភាព មុនពេលឱ្យប្រើប្រាស់ ។

## ១៥~ ការងារ

ក- មានតែទណ្ឌិតប៉ុណ្ណោះ ត្រូវបានគេដឹកនាំឱ្យធ្វើការ ។

ខ- ពិរុទ្ធជន មិនត្រូវបានគេដឹកនាំឱ្យធ្វើការទេ លើកលែងតែមានការស្ម័គ្រចិត្ត ។

គ- សកម្មភាពការងារក្នុងពន្ធនាគារ ដែលមិនបណ្តាលឱ្យមានការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្តត្រូវមានការអនុញ្ញាតពីប្រធាននាយកដ្ឋានពន្ធនាគារ ។ ការងាររបស់ពន្ធនាគារ ត្រូវធ្វើទៅតាមលក្ខណៈធម្មតា ដោយផ្តល់នូវជំនាញមានប្រយោជន៍ដល់អ្នកទោស ឆ្លើយតបទៅនឹងរបៀបរៀបរយល្អ សន្តិសុខ និងការងារដែលមានក្នុងពន្ធនាគារ ។

ឃ- អ្នកទោសធ្វើការ ត្រូវទទួលផលកម្រៃបន្ថែម តាមការណែនាំរបស់ប្រធាននាយកដ្ឋានពន្ធនាគារ ហើយត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រី ។ ការងាររបស់អ្នកទោសខាងលើនេះ មិនរាប់បញ្ចូលការថែទាំអនាម័យផ្ទាល់ខ្លួន ការសំអាតជាប្រចាំ ការថែទាំសម្លៀកបំពាក់ និងសម្ភារៈបរិក្ខារ គឺជាការទទួលខុសត្រូវរបស់អ្នកទោសម្នាក់ៗ ។

ង- ទណ្ឌិតដែលមានជម្ងឺ ឬមានវ័យចាស់ជរា មិនត្រូវដឹកនាំឱ្យធ្វើការឡើយ ។

ច- មិនត្រូវឱ្យទណ្ឌិតស្ត្រី ធ្វើការក្នុងរយៈពេល៩០ថ្ងៃ មុន និងក្រោយពេលសម្រាលកូនដែលច្បាប់ហាមឃាត់ ។

ឆ- អ្នកទោសជាឧក្រិដ្ឋជន ឬអ្នកធ្លាប់ជាប់ពន្ធនាគារ ឬក៏អ្នកធ្លាប់ធ្វើសកម្មភាពរត់ មិនអនុញ្ញាតឱ្យចេញក្រៅ ធ្វើពលកម្មឡើយ ។

ជ- ការងារពលកម្មរបស់អ្នកទោស ត្រូវធ្វើតាមការកំណត់របស់ប្រធានពន្ធនាគារ ។ មិនអនុញ្ញាតឱ្យធ្វើពលកម្មដើម្បីផលប្រយោជន៍របស់បុគ្គល ឬឯកជនឡើយ ។

## ១៦. ការឧបត្ថម្ភផ្នែកសាសនា

ក- ប្រធានពន្ធនាគារ ត្រូវអនុញ្ញាតឱ្យអ្នកតំណាងសាសនា មានសិទ្ធិចូលក្នុងពន្ធនាគារ ដើម្បីផ្តល់ដំបូន្មានផ្នែកសាសនា និងឧបត្ថម្ភខាងផ្លូវចិត្តដល់អ្នកទោស ។ អ្នកទោសគ្រប់រូបមិនត្រូវបានគេបង្ខំឱ្យជួបជាមួយអ្នកតំណាងសាសនាណាម្នាក់ ដែលផ្ទុយនឹងឆន្ទៈរបស់ពួកគេឡើយ ។

ខ- ពិធីបុណ្យសាសនា អាចត្រូវបានអនុញ្ញាតយល់ព្រមពីប្រធានពន្ធនាគារ ។

## ១៧. មរណភាព

ក- នៅពេលមានអ្នកទោសស្លាប់ ប្រធានពន្ធនាគារត្រូវជូនដំណឹងជាបន្ទាន់ ទៅព្រះរាជអាជ្ញា និងប្រធាននាយកដ្ឋានពន្ធនាគារ ។

ខ- ក្នុងអំឡុងពេល៣ថ្ងៃ នៃមរណភាព ប្រធានពន្ធនាគារត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីមរណភាពអ្នកទោសនោះទៅកាន់ :

- ប្រធាននាយកដ្ឋានពន្ធនាគារ ។
- មន្ត្រីអគ្គានុកូលដ្ឋាននៃកន្លែងរស់នៅរបស់អ្នកទោស តាមនីតិវិធីពន្ធនាគារ ។

- ស្ថានទូត ឬស្ថានកុងស៊ុលដែលពាក់ព័ន្ធ បើសិនជាអ្នកទោសជាជនបរទេស ដើម្បីជូនដំណឹងជាបន្ទាន់ទៅក្រុមគ្រួសារអ្នកទោសនោះ ។

គ- ប្រធានពន្ធនាគារត្រូវថតចម្លងលិខិតមរណភាពរបស់អ្នកទោសមួយច្បាប់ បន្ទាប់ពីមរណភាពនោះ ហើយត្រូវដាក់ជូនលិខិតនេះទៅប្រធាននាយកដ្ឋាន ។

ឃ- ប្រធានពន្ធនាគារមិនត្រូវរៀបចំរំកិលសាកសពអ្នកទោស ដែលស្លាប់ក្នុងពន្ធនាគារ លុះណាតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា ឬនគរបាលយុត្តិធម៌ ។

ង- នាយកដ្ឋានពន្ធនាគារ ត្រូវសហការជាមួយអាជ្ញាធរសុខាភិបាល ដើម្បីរៀបចំពិធីបុណ្យសពអ្នកទោស បើសិនជា :

- សាកសពដែលគេមិនស្គាល់គ្រួសារ ។
- ស្នើដោយគ្រួសារសាកសព ស្ថានទូត ឬស្ថានកុងស៊ុល ។

ច- អ្នកទោសគ្រប់រូប ដែលទទួលមរណភាព ត្រូវមានរបបគោលនយោបាយបច្ឆាមរណៈ ។

## ១៨- កូនរបស់អ្នកទោសស្ត្រី

ក- បើសិនអ្នកទោសស្ត្រីមានផ្ទៃពោះ :

- ត្រូវផ្ដល់កិច្ចឧបត្ថម្ភជាពិសេស ដើម្បីថែទាំសុខភាពរបស់ស្ត្រីនោះ មុន និងក្រោយពេលសម្រាលកូន ។
- ត្រូវអនុញ្ញាតឱ្យអ្នកទោសសម្រាលកូននៅមន្ទីរពេទ្យខាងក្រៅពន្ធនាគារ ។
- បើសិនជាអ្នកទោសស្ត្រីសម្រាលកូននៅក្នុងពន្ធនាគារ អ្នកថែទាំសុខភាពម្នាក់ ត្រូវចូលរួមពិនិត្យសុខភាពអ្នកទោសជាម្ដាយ និងកូននោះយ៉ាងឆាប់ ដែលអាចធ្វើទៅបាន បន្ទាប់ពីសម្រាលកូនរួច ។
- បើសិនជាទារកកើតនៅក្នុងពន្ធនាគារ ទីកន្លែងកំណើត មិនត្រូវចុះនៅក្នុងសំបុត្រកំណើតថា ទារកនោះកើតនៅក្នុងពន្ធនាគារឡើយ ។

ខ- កូនអាចរស់នៅជាមួយម្ដាយក្នុងពន្ធនាគារបាន រហូតដល់ពួកគេមានអាយុ ៦ឆ្នាំ ។ ក្នុងអំឡុងពេលនោះ ម្ដាយត្រូវទទួលខុសត្រូវក្នុងការថែទាំសុវត្ថិភាពកូន ។ នាយកដ្ឋានពន្ធនាគារត្រូវផ្ដល់ម្ហូបអាហារ ថ្នាំសង្កូវដល់កុមារទាំងនោះ នៅពេលពួកគេរស់នៅក្នុងពន្ធនាគារ ។ បើសិន

ជាគេអនុញ្ញាតឱ្យកុមារទាំងនោះ រស់នៅក្នុងពន្ធនាគារ ត្រូវអនុញ្ញាតឱ្យពួកគេចេញចូលតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ។

គ- ក្នុងករណីដែលក្មេងទាំងនោះ មិនអាចរស់នៅក្នុងពន្ធនាគារបាន ឧទាហរណ៍ៈ នៅពេលម្ដាយមានជម្ងឺធ្ងន់ មិនអាចថែទាំពួកគេបាន ដើម្បីផលប្រយោជន៍ល្អប្រសើរដល់ក្មេងទាំងនោះ ប្រធានពន្ធនាគារត្រូវទំនាក់ទំនងជាមួយក្រសួងមានសមត្ថកិច្ចទទួលខុសត្រូវ ឬគ្រួសារ សាច់ញាតិ ដើម្បីឱ្យគេទទួលយកក្មេងទាំងនោះទៅបីបាច់ថែរក្សានៅក្រៅពន្ធនាគារ រួចហើយត្រូវរាយការណ៍ជូននាយកដ្ឋានពន្ធនាគារ ។

## ១៩. កម្មវិធី

កម្មវិធីសម្រាប់អ្នកទោស ត្រូវផ្ដល់ទៅជនណាដែលមានគុណសម្បត្តិគ្រប់គ្រាន់ ហើយមានការអនុញ្ញាតយល់ព្រមពីប្រធាននាយកដ្ឋាន ដើម្បី :

- លើកស្ទួយសុខភាពអ្នកទោស ។
- អប់រំអ្នកទោសឱ្យគោរពច្បាប់ និងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ។
- បង្រៀនលេខ អក្សរ និងបណ្ដុះបណ្ដាលមុខជំនាញបច្ចេកទេសផ្នែកវិជ្ជាជីវៈ ។
- អប់រំអ្នកទោស អំពីសេចក្ដីថ្លៃថ្នូរក្នុងសង្គម និងអាកប្បកិរិយា សីលធម៌រស់នៅ ។

## ២០ ការលើកលែងទោស និងបន្ធូរទោស

ក- ទណ្ឌិតអាចត្រូវបានលើកលែងទោស ឬបន្ធូរទោស ស្របតាមច្បាប់ ឬ លិខិតបទដ្ឋាននានានៃព្រះរាជាណាចក្រកម្ពុជា ។

ខ- ប្រធានពន្ធនាគារ ត្រូវរៀបចំធ្វើបញ្ជីទណ្ឌិត ដែលត្រូវលើកលែងទោស ឬបន្ធូរទោស ហើយត្រូវដាក់បញ្ជីនោះ ជូនតុលាការតាមនីតិវិធីពន្ធនាគារ ។

## ២១. សេចក្ដីរាយការណ៍អំពីឧប្បត្តិហេតុ

មន្ត្រីពន្ធនាគារ ត្រូវរាយការណ៍ជាបន្ទាន់ ជូនប្រធានពន្ធនាគារ អំពីឧប្បត្តិហេតុទាក់ទងនឹងសន្តិសុខ កិច្ចប្រតិបត្តិការ រដ្ឋបាលពន្ធនាគារ ឬការគ្រប់គ្រងអ្នកទោស ។ ក្នុងករណីធ្ងន់ធ្ងរ

ប្រធានពន្ធនាគារត្រូវរាយការណ៍ទៅប្រធាននាយកដ្ឋានពន្ធនាគារ ដោយអនុវត្តតាមនីតិវិធីពន្ធនាគារ ។

## ២២. វិន័យរបស់អ្នកទោស

ក- ប្រធាននាយកដ្ឋាន ត្រូវចុះបញ្ជីរាល់សកម្មភាពទាំងឡាយ ដែលអ្នកទោសបំពានលើបទវិន័យពន្ធនាគារ និងត្រូវចេញនីតិវិធីដើម្បីដោះស្រាយបញ្ហានេះ ។

ខ- មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារ ត្រូវប្រកាន់អាកប្បកិរិយា និងវិន័យថ្លៃថ្នូរ ចំពោះអ្នកទោស ។ បទវិន័យត្រូវធ្វើឡើងដោយគោរពសិទ្ធិអ្នកទោស និងជៀសវាងការដាក់ទណ្ឌកម្ម ឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកឡើយ ។

គ- មិនត្រូវដាក់វិន័យពីរដង ចំពោះបទល្មើសដូចគ្នា ហើយក៏មិនត្រូវដាក់ទណ្ឌកម្មរួមចំពោះអ្នកទោសណាម្នាក់ឡើយ ។

## ២៣. ការប្រើប្រាស់កម្លាំង និងអាវុធ

ក- ក្នុងពេលបំពេញភារកិច្ច មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារ ត្រូវប្រើប្រាស់មធ្យោបាយ អហិង្សាមុនពេលប្រើប្រាស់កម្លាំង បើសិនអាចធ្វើបាន ។ មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារ អាចប្រើប្រាស់កម្លាំងដែលបានកំណត់ និងមានសមាមាត្រ ដើម្បីទប់ស្កាត់ការរត់គេចខ្លួន ស្វ័យការពារ ឬការពារជនដទៃទៀត ដើម្បីទប់ទល់នឹងកម្លាំងអ្នកទោស ។

ខ- ប្រធាននាយកដ្ឋានពន្ធនាគារ ត្រូវកំណត់ប្រភេទអាវុធ និងគ្រាប់រំសេវ ដែលត្រូវបើកឱ្យប្រើប្រាស់នៅតាមពន្ធនាគារនានា ដោយមានការយល់ព្រមពីរដ្ឋមន្ត្រី ។

គ- ប្រធានពន្ធនាគារ ត្រូវបើកអាវុធ និងគ្រាប់រំសេវឱ្យមន្ត្រីពន្ធនាគារ ប្រើប្រាស់ក្នុងពេលបំពេញភារកិច្ចតាមការកំណត់ ដោយអនុលោមតាមនីតិវិធីពន្ធនាគារ ។

ឃ- មិនត្រូវប្រើប្រាស់អាវុធ លើកលែងតែក្នុងករណីមិនអាចជៀសវាងបាន ដូចជាក្នុងកិច្ច ស្វ័យការពារ ឬកិច្ចការផ្សេងទៀត ដែលស្ថិតក្នុងកាលៈទេសៈដូចតទៅនេះ :

- ក្នុងករណីមានការគម្រាមកំហែងដល់អាយុជីវិត ឬរបួសធ្ងន់ធ្ងរ ។
- ដើម្បីទប់ស្កាត់បទល្មើសធ្ងន់ធ្ងរ ពាក់ព័ន្ធនឹងការគម្រាមកំហែងដល់អាយុជីវិត ។

- ដើម្បីទប់ស្កាត់ការរត់គេចខ្លួន ក្នុងករណីដែលការប្រើប្រាស់មធ្យោបាយតិចតួច មិនអាចធ្វើទៅបាន និងក្នុងការការពារជនណាម្នាក់ ដែលទទួលការគម្រាមកំហែងដល់អាយុជីវិត បង្កឡើងដោយអ្នកទោសដែលកំពុងរត់គេចខ្លួន ។

## ២៤. ការឆែកឆេរ

ក- ប្រធានពន្ធនាគារ ត្រូវបញ្ជាឱ្យមន្ត្រីពន្ធនាគារត្រួតពិនិត្យឆែកឆេរ :

- ខ្លួនប្រាណ សម្ភារៈ បន្ទប់ អគារ ទីកន្លែងស្នាក់នៅធ្វើការងាររបស់អ្នកទោសជាទៀងរាល់ថ្ងៃ និងគ្រប់ពេលវេលា ។
- ត្រួតពិនិត្យឆែកឆេរអ្នកមកសួរសុខទុក្ខ វត្ថុ ឬសម្ភារៈរបស់ពួកគេ បើសិនជាការត្រួតពិនិត្យ ឆែកឆេរនេះ ដើម្បីរក្សាសន្តិសុខ សុវត្ថិភាពក្នុងពន្ធនាគារ ។

ខ- រាល់ការឆែកឆេរជនទាំងនោះ ត្រូវធ្វើឡើងដោយមន្ត្រីពន្ធនាគារ ដែលមានភេទដូចគ្នា តាមជំនាញ ជៀសវាងការប្រើប្រាស់កម្លាំងមិនចាំបាច់ ប៉ះពាល់ការអៀនខ្មាស់ សេចក្តីថ្លៃថ្នូររបស់ជននោះ ។ មិនត្រូវបញ្ជាឱ្យជនដែលត្រូវគេឆែកឆេរដោះ សម្លៀកបំពាក់ ឬវត្ថុផ្សេងៗក្រៅពីស្បែកជើងឡើយ ។

គ- អ្នកទោសដែលមិនព្រមឱ្យគេឆែកឆេរ ត្រូវទទួលទណ្ឌកម្ម តាមវិន័យ ។

ឃ- មុនធ្វើការឆែកឆេរ ត្រូវប្រាប់អ្នកមកសួរសុខទុក្ខ ពីនីតិវិធីនៃការឆែកឆេរ ហើយបើសិនជាអ្នកមកសួរសុខទុក្ខនោះ បដិសេធមិនព្រមឱ្យឆែកឆេរ ពួកគេមិនត្រូវបានអនុញ្ញាតឱ្យចូលឬឱ្យចេញពីពន្ធនាគារឡើយ ។

## ២៥. ការប្រើប្រាស់ខ្នោះដៃ

ក- ខ្នោះដៃ គឺគ្រាន់តែជាឧបករណ៍ដែលគេប្រើសម្រាប់បង្ខាំងអ្នកទោស ហើយមិនត្រូវប្រើប្រាស់ក្នុងទម្រង់ណាមួយ នៃការដាក់ទណ្ឌកម្មឡើយ ។

ខ- ប្រធានពន្ធនាគារ អាចបញ្ជាឱ្យប្រើប្រាស់ខ្នោះដៃ ក្នុងកាលៈទេសៈដូចខាងក្រោម :

- បង្ការការរត់គេចខ្លួន ។
- វិធានការផ្សេងទៀត មិនបានសម្រេចក្នុងការរារាំងអ្នកទោស មិនឱ្យបង្ករបួសស្នាមខ្លួនឯង អ្នកដទៃ ឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិទូទៅ ។

គ- មិនត្រូវប្រើខ្នោះដៃសម្រាប់រយៈពេលយូរជាងសេចក្តីត្រូវការជាចាំបាច់ ហើយត្រូវធ្វើការត្រួតពិនិត្យយ៉ាងទៀងទាត់ ដើម្បីធានាថា ខ្នោះដៃទាំងនោះមានសុវត្ថិភាព ហើយអ្នកទោសមិនទទួលការឈឺចាប់ ដោយការប្រើប្រាស់ខ្នោះដៃនោះទេ ។

## ២៦. ការពិនិត្យពន្ធនាគារ

ក- ជនទាំងឡាយដូចខាងក្រោមនេះ អាចអនុញ្ញាតឱ្យចូលក្នុងពន្ធនាគារបាន :

- តំណាងព្រះមហាក្សត្រ
- សមាជិករដ្ឋសភាជាតិ
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ជនទាំងឡាយ ដែលអនុញ្ញាតពីក្រសួងមហាផ្ទៃ
- ចៅក្រម ឬព្រះរាជអាជ្ញា
- អភិបាលខេត្ត-ក្រុង
- ជនណាម្នាក់ ឬអង្គការណាមួយ ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី ប្រធាននាយកដ្ឋានពន្ធនាគារ ។

ខ- ជនទាំងឡាយ ដែលមានចែងនៅក្នុងចំណុច លេខ ២៦.ក គួរជូនដំណឹងទៅប្រធាននាយកដ្ឋានទាក់ទងបញ្ហាពិធីការមុនពេលចូលទស្សនកិច្ច ។

គ- ជនណាម្នាក់ ឬអង្គការណាមួយ ដែលបានអនុញ្ញាតពីប្រធាននាយកដ្ឋានពន្ធនាគារឱ្យចូលពន្ធនាគារត្រូវអនុវត្តតាមលក្ខខ័ណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរនោះ ។

ឃ- បើមិនគោរពតាមលក្ខខ័ណ្ឌចែងក្នុងលិខិតអនុញ្ញាត ប្រធាននាយកដ្ឋានពន្ធនាគារអាចកែប្រែ ឬលុបចោល ការអនុញ្ញាតដែលមានស្រាប់ ។

ង- ជនទាំងឡាយណា ដែលគេអនុញ្ញាតឱ្យចូលក្នុងពន្ធនាគារ បើរកឃើញថា មានបញ្ហាណាមួយ ឬបញ្ហាចម្បងផ្សេងទៀត ក្នុងការគ្រប់គ្រងពន្ធនាគារ ឬការថែទាំអ្នកទោស ជននោះត្រូវធ្វើសេចក្តីរាយការណ៍ទៅប្រធានពន្ធនាគារ ឬប្រធាននាយកដ្ឋាន ។ ប្រធាននាយកដ្ឋានពន្ធនាគារ ត្រូវរាយការណ៍ជូនថ្នាក់លើ ។

## ២៧- ការឧបត្ថម្ភផ្នែកពេទ្យ

ក- ពន្ធនាគារនីមួយៗ ត្រូវមានអ្នកថែទាំសុខភាព ដែលមានភារកិច្ចទទួលខុសត្រូវ :

- ការថែទាំសុខភាពអ្នកទោស ។
- ការផ្តល់ជំនួយសង្គ្រោះបន្ទាន់ផ្នែកពេទ្យ ។
- ការពិនិត្យសុខភាពអ្នកទោស ។
- ការពិនិត្យអនាម័យនៅក្នុងពន្ធនាគារ យ៉ាងហោចណាស់ឱ្យបាន ៣ខែម្តង ហើយត្រូវរាយការណ៍ទៅប្រធានពន្ធនាគារ និងប្រធាននាយកដ្ឋានក្នុងអម្លុងពេល ៧ថ្ងៃ ។
- ក្នុងការរាយការណ៍ទៅប្រធានពន្ធនាគារ នៅពេលអ្នកទោសឈឺធ្ងន់ បណ្តាលមកពីការឃុំឃាំង ។
- លើសកម្មភាពទាក់ទងនឹងសុខភាព ដូចបានណែនាំពីប្រធាននាយកដ្ឋាន ។

ខ- មន្ត្រីពន្ធនាគារទាំងអស់ត្រូវទទួលការហ្វឹកហ្វឺន ផ្នែកបឋមសង្គ្រោះជាមូលដ្ឋាន និងបណ្តុះបណ្តាលឡើងវិញ យ៉ាងហោចណាស់ឱ្យបាន ៣ឆ្នាំ ម្តង ។

**ប្រការ ៥: និរាករណ៍**

បទបញ្ញត្តិនៃប្រកាសផ្សេងៗ ដែលមានពីមុនមក ពាក់ព័ន្ធដល់ការគ្រប់គ្រងពន្ធនាគារ និងមានខ្លឹមសារផ្ទុយពីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦: ស្ថាប័នអនុវត្ត:**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកនគរបាលជាតិ អគ្គាធិការ ក្រសួងមហាអភិបាលខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ។

**ប្រការ ៧: ការចូលជាធរមាន:**

ប្រកាសនេះ ត្រូវចាប់អនុវត្តពីថ្ងៃចុះហត្ថលេខា តទៅ ។

ភ្នំពេញ, ថ្ងៃទី ...... ខែ ...... ឆ្នាំ ១៩៩៩

រដ្ឋមន្ត្រី

ឧបសម្ព័ន្ធ ក

## ពន្ធនាគារដែលមាន

| ល.រ | ពន្ធនាគារ | ទីតាំងពន្ធនាគារ |
|---|---|---|
| ១ | ភ្នំពេញ T-3 | ក្រុងភ្នំពេញ |
| ២ | ភ្នំពេញ PJ | ក្រុងភ្នំពេញ |
| ៣ | ភ្នំពេញ ព្រៃសរ | ក្រុងភ្នំពេញ |
| ៤ | ត្រពាំងផ្លុង T-5 | ខេត្តកំពង់ចាម |
| ៥ | កំពង់ស្ពឺ | ខេត្ត កំពង់ស្ពឺ |
| ៦ | ក្រុងព្រះសីហនុ | ក្រុងព្រះសីហនុ |
| ៧ | កំពត | ខេត្ត កំពត |
| ៨ | កំពង់ឆ្នាំង | ខេត្ត កំពង់ឆ្នាំង |
| ៩ | កណ្ដាល តាខ្មៅ | ខេត្ត កណ្ដាល |
| ១០ | កំពង់ចាម | ខេត្ត កំពង់ចាម |
| ១១ | ព្រៃវែង | ខេត្ត ព្រៃវែង |
| ១២ | ពោធិសាត់ | ខេត្ត ពោធិសាត់ |
| ១៣ | កំពង់ធំ | ខេត្ត កំពង់ធំ |
| ១៤ | ព្រះវិហារ | ខេត្ត ព្រះវិហារ |
| ១៥ | បន្ទាយមានជ័យ | ខេត្ត បន្ទាយមានជ័យ |
| ១៦ | បាត់ដំបង | ខេត្ត បាត់ដំបង |
| ១៧ | កោះកុង | ខេត្ត កោះកុង |
| ១៨ | សៀមរាប | ខេត្ត សៀមរាប |
| ១៩ | ស្វាយរៀង | ខេត្ត ស្វាយរៀង |
| ២០ | ស្ទឹងត្រែង | ខេត្ត ស្ទឹងត្រែង |
| ២១ | ក្រចេះ | ខេត្ត ក្រចេះ |
| ២២ | តាកែវ | ខេត្ត តាកែវ |
| ២៣ | មណ្ឌលគិរី | ខេត្ត មណ្ឌលគិរី |
| ២៤ | រតនគិរី | ខេត្ត រតនគិរី |

ភ្នំពេញ, ថ្ងៃទី...៣/......ខែ...[illegible]......ឆ្នាំ ១៩៩៥.

រដ្ឋមន្ត្រី